ស្ថានបេសកកម្មអចិន្ត្រៃយ៍នៃព្រះរាជាណាចក្រកម្ពុជា
ប្រចាំអង្គការសហប្រជាជាតិ និងអង្គការអន្តរជាតិនានា នៅហ្សឺណែវ

# បទអន្តរាគមន៍របស់
# ឯកអគ្គរាជទូត និងជាតំណាងអចិន្ត្រៃយ៍កម្ពុជា អាន សុខខឿន
# នៅសម័យប្រជុំលើកទី៤៥ នៃក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ
# របៀបវារៈទី១០៖ របាយការណ៍របស់អគ្គលេខាធិការ អង្គការសហប្រជាជាតិ ស្តីពី តួនាទី និងសមិទ្ធផលនៃការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិ ទទួលបន្ទុកសិទ្ធិមនុស្ស នៅកម្ពុជា
# ថ្ងៃទី០៥ ខែតុលា ឆ្នាំ២០២០ នៅហ្សឺណែវ
# [រយៈពេលថ្លែង ៥នាទី]

ឯកឧត្តមអនុប្រធានក្រុមប្រឹក្សាសិទ្ធិមនុស្ស!

១. ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិ ទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ប្រចាំកម្ពុជា ដែលជាការិយាល័យមានវ័យចំណាស់ជាងគេបំផុតនៅលើពិភពលោក បាននិងកំពុងទទួលបាននូវកិច្ចសហប្រតិបត្តិការដោយបើកចំហនិងស្មោះត្រង់ពីរាជរដ្ឋាភិបាលកម្ពុជា ដូចដែលអគ្គលេខាធិការអង្គការសហប្រជាជាតិ (អ.ស.ប) បានទទួលស្គាល់ នៅក្នុងរបាយការណ៍ដែលយកមកពិភាក្សា នាពេលនេះ ។

២.គណៈប្រតិភូយើងខ្ញុំ សូមអរគុណចំពោះសេវាកម្មប្រឹក្សាយោបល់របស់ OHCHR នាពេលកន្លងមក ។ យើងខ្ញុំបន្តរក្សាទស្សនៈថា កិច្ចសហប្រតិបត្តិការបច្ចេកទេសត្រូវតែកំណត់និងសម្រេចដោយផ្អែកតាមតម្រូវការរបស់រដ្ឋពាក់ព័ន្ធ ហើយត្រូវស្របទៅនឹងគោលដៅនិងអាទិភាពជាតិ ដោយគិតគូរពីស្ថានភាពជាក់ស្តែងរបស់ប្រទេស និងពីតួនាទីចម្បងរបស់រដ្ឋក្នុងនាមជាអ្នកកាន់កាតព្វកិច្ចក្នុងកិច្ចការពារសិទ្ធិមនុស្ស។

៣. វាជាការចាំបាច់ណាស់ដែល OHCHR ត្រូវអនុវត្តអាណត្តិរបស់ខ្លួនដោយអនុលោមតាមសេចក្តីសម្រេចចិត្តរបស់មហាសន្និបាតអ.ស.ប (A/RES/48/141) ស្តីពីការបង្កើតការិយាល័យនេះ ហើយដែលកំណត់ឱ្យ OHCHR ប្រតិបត្តិការស្របតាមធម្មនុញ្ញរបស់អ.ស.ប និងមានកាតព្វកិច្ចគោរពអធិបតេយ្យភាព និងដែនសមត្ថកិច្ចក្នុងស្រុករបស់រដ្ឋ ដែលខ្លួនកំពុងប្រតិបត្តិការ។

៤. ការឆ្លើយតបរបស់ប្រទេសកម្ពុជាចំពោះជំងឺកូវីដ១៩ ដែលអនុលោមតាមគោលការណ៍ណែនាំរបស់អង្គការសុខភាពពិភពលោក មានគោលដៅធានាថា ជីវិតដ៏មានតម្លៃមិនអាចកាត់

ថ្លៃបានរបស់មនុស្សគ្រប់រូប នឹងមិនត្រូវបានបាត់បង់ឡើយ។ រាល់វិធានការដែលបានដាក់ចេញកន្លងមក បានគោរពតាមនីតិវិធីត្រឹមត្រូវ និងប្រកាន់ខ្ជាប់នូវគោលការណ៍នីត្យានុកូលភាព ភាពចាំបាច់ និងភាពសមាមាត្រ។ វិធានការទាំងនេះដែលសំដៅការពារសិទ្ធិរបស់ពលរដ្ឋគ្រប់រូបឱ្យរស់នៅ ដោយគ្មានការភ័យខ្លាច ការស្អប់ខ្ពើម និងការរើសអើង មិនគួរត្រូវបានបកស្រាយថា ជាការបំបិទសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ និងប្រព័ន្ធផ្សព្វផ្សាយឡើយ។ អគ្គលេខាធិការ អ.ស.ប António Guterres បានគូសបញ្ជាក់ថា ព័ត៌មានក្លែងក្លាយនិងសារស្អប់ខ្ពើម គឺជាការវាយប្រហារទៅលើខ្លឹមសារនៃបទដ្ឋាននិងគោលការណ៍សិទ្ធិមនុស្ស។

៥. ជាលទ្ធផល ប្រទេសកម្ពុជាអាចគ្រប់គ្រងជំងឺកូវីដ១៩ បាន ដោយគិតត្រឹមថ្ងៃទី០៥ ខែតុលា ឆ្នាំ ២០២០ មានករណីឆ្លងចំនួន២៨០ គ្មានអ្នកស្លាប់ គ្មានសញ្ញានៃការឆ្លងក្នុងសហគមន៍ និងគ្មានការបិទប្រទេស នាពេលកន្លងមក។

៦. កម្ពុជាក៏បានដាក់ចេញនូវកិច្ចអន្តរាគមន៍គាំពារសង្គម ដើម្បីទ្រទ្រង់ជីវភាពរស់នៅរបស់ពលរដ្ឋជនបទ ក្រីក្រ គ្រួសារងាយរងគ្រោះ ជនពិការ ស្ត្រីមានផ្ទៃពោះ និងកុមារ ព្រមទាំង និយោជិកដែលត្រូវបានព្យួរពីការងារ តាមរយៈកម្មវិធីសាច់ប្រាក់សម្រាប់ការងារ កម្មវិធីឧបត្ថម្ភសាច់ប្រាក់ និងកញ្ចប់គាំទ្រប្រាក់ចំណូល។

ឯកឧត្តមអនុប្រធានក្រុមប្រឹក្សាសិទ្ធិមនុស្ស!

៧. ច្បាប់ទាំងអស់របស់កម្ពុជាត្រូវបានសិក្សានិងរៀបចំដោយយកចិត្តទុកដាក់ ដោយផ្អែកលើគម្រូតាមបណ្តាប្រទេសនិងតំបន់ផ្សេងៗ និងសម្របតាមស្ថានភាពរបស់កម្ពុជា។ ច្បាប់ស្តីពី ការគ្រប់គ្រងប្រទេសក្នុងគ្រាអាសន្ន ដែលប្រកាន់ខ្ជាប់នូវគោលការណ៍នៃនីត្យានុកូលភាព ភាពសមាមាត្រ និងភាពចាំបាច់ នៅមិនទាន់យកមកអនុវត្តម្តងណាឡើយ។ ហើយប្រសិនបើចាំបាច់ត្រូវប្រកាសដាក់ប្រទេសក្នុងគ្រាអាសន្ន ច្បាប់នេះតម្រូវឱ្យមានការឯកភាពកុងសង់ស៊ីសពីនាយករដ្ឋមន្ត្រី ប្រធានរដ្ឋសភា ប្រធានព្រឹទ្ធសភា និងព្រះមហាក្សត្រ ដែលយន្តការនេះឆ្លុះបញ្ចាំងពីតុល្យភាពនិងការត្រួតពិនិត្យនៃអំណាចនៅកម្ពុជា។

៨. តាមសំណើរបស់គ្រប់ភាគីពាក់ព័ន្ធទាំងអស់ ច្បាប់សហជីពត្រូវបានធ្វើវិសោធនកម្ម ដោយអនុលោមតាមអនុសញ្ញារបស់អង្គការអន្តរជាតិខាងការងារ។ សេចក្តីព្រាងច្បាប់ស្តីពី សិទ្ធិទទួលបានព័ត៌មាន ដែលនឹងត្រូវបញ្ជូនទៅទីស្តីការគណៈរដ្ឋមន្ត្រីសម្រាប់ការអនុម័ត ឆាប់ៗខាងមុខនេះ ត្រូវបានពិគ្រោះយោបល់យ៉ាងទូលំទូលាយជាមួយអ្នកពាក់ព័ន្ធទាំងអស់ រួមទាំងអង្គការសង្គមស៊ីវិល និងទីភ្នាក់ងារអង្គការសហប្រជាជាតិ។

៩. រាជរដ្ឋាភិបាល កំពុងពិនិត្យនិងសិក្សាអំពីនីត្យានុកូលភាពនៃសំណើធ្វើវិសោធនកម្មលើមាត្រាចំនួន១៤ នៃច្បាប់ស្តីពី សមាគម និងអង្គការមិនមែនរដ្ឋាភិបាល។ ដូចប្រទេសដទៃទៀតដែរ វត្តមានរបស់មន្ត្រីនគរបាលនៅក្បែរទីកន្លែងរៀបចំព្រឹត្តិការណ៍ផ្សេងៗ មិនគួរត្រូវបានបកស្រាយថាជា ការបំភិតបំភ័យឬការរំខានឡើយ។ មន្ត្រីគ្រាន់តែបំពេញភារកិច្ចរបស់ខ្លួន ដើម្បីបង្ការភាពចលាចល ឬអសន្តិសុខនានា ដែលអាចកើតមានឡើងជាយថាហេតុ។ ពួកគាត់បានទទួលនូវការណែនាំយ៉ាងច្បាស់ ឱ្យជួយសម្រួលរាល់សកម្មភាពស្របច្បាប់ របស់អង្គការសង្គមស៊ីវិល។ រាជរដ្ឋាភិបាលនៅបន្តប្តេជ្ញាចិត្តក្នុងការដោះស្រាយរាល់បញ្ហាប្រឈមនានាដែលអង្គការសង្គមស៊ីវិលជួបប្រទះ តាមរយៈ វេទិកាភាពជាដៃគូ ដែលបានរៀបចំជាទៀងទាត់។

១០. រាជរដ្ឋាភិបាលកម្ពុជាពុំមានគោលនយោបាយបណ្តេញពលរដ្ឋចេញពីទីតាំងដីដោយបង្ខំទេ។ ផ្ទុយទៅវិញ រាជរដ្ឋាភិបាលតែងតែផ្តោតយកចិត្តទុកដាក់លើគ្រួសារក្រីក្រនិងគ្មានដី។ វិធានការមួយចំនួនត្រូវបានដាក់ចេញ ដើម្បីធានាសិទ្ធិកាន់កាប់ដីធ្លី និងកាត់បន្ថយទំនាស់ដីធ្លី។ នៅដើមឆ្នាំនេះ ៨១% នៃប័ណ្ណកម្មសិទ្ធិចំនួន៧លាន ត្រូវបានចុះបញ្ជីដោយជោគជ័យ។ រាជរដ្ឋាភិបាលប្តេជ្ញាចិត្តចុះបញ្ជីឱ្យបានចប់ទាំងអស់នៅឆ្នាំ២០២១ ។ ប្រទេសកម្ពុជាត្រូវបានគេទទួលស្គាល់ថាជាប្រទេសឈានមុខគេមួយក្នុងទ្វីបអាស៊ីដែលបានទទួលស្គាល់អត្តសញ្ញាណ និងបានចុះបញ្ជីកម្មសិទ្ធិដីធ្លីរបស់សហគមន៍ជនជាតិដើមភាគតិច។

១១. កម្ពុជាបន្តយកចិត្តទុកដាក់លើកិច្ចការពារសិទ្ធិរបស់បុគ្គលដែលត្រូវបានដកហូតសេរីភាព។ យុទ្ធនាការរបស់ក្រសួងយុត្តិធម៌សំដៅដោះស្រាយការកកស្ទះសំណុំរឿងនៅតាមតុលាការ បានសម្រេចលទ្ធផលបានលើស ៦៥% រួចហើយ ដែលបានចូលរួមដោះស្រាយស្ថានភាពចង្អៀតណែនក្នុងពន្ធនាគារ។ វិធានការបង្ការ ត្រូវបានដាក់ចេញផងដែរ ដើម្បីទប់ស្កាត់ការរីករាលដាលជំងឺកូវីដ១៩ នៅតាមពន្ធនាគារ។ ការសម្ភាសន៍សម្ងាត់ជាមួយជនជាប់ឃុំ អាចប្រព្រឹត្តទៅបានដោយអនុលោមតាមច្បាប់ពន្ធនាគាររបស់ប្រទេសកម្ពុជា និងកាតព្វកិច្ចក្រោមអនុសញ្ញាអន្តរជាតិពាក់ព័ន្ធ ដែលកម្ពុជា ជារដ្ឋភាគី។

ឯកឧត្តមអនុប្រធានក្រុមប្រឹក្សាសិទ្ធិមនុស្ស!

១២. គណៈប្រតិភូយើងខ្ញុំនៅតែបន្តទស្សនៈថា សេរីភាពបញ្ចេញមតិ បង្កើតសមាគម និងប្រមូលផ្តុំដោយសន្តិវិធី មិនគួរយកមកពិភាក្សាដាច់ដោយឡែក និងផ្តាច់ចេញពីកាតព្វកិច្ចរបស់ម្ចាស់សិទ្ធិនោះទេ។ កតិកាសញ្ញាអន្តរជាតិស្តីពី សិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ សង្កត់ធ្ងន់ថា ការអនុវត្តសេរីភាពទាំងនោះត្រូវភ្ជាប់មកជាមួយនូវករណីកិច្ច ការទទួលខុសត្រូវពិសេស និងដែនកំណត់ ដែលមានចែងក្នុងច្បាប់។ ដូច្នេះ ការវាយតម្លៃអំពីស្ថានភាពនៅប្រទេសកម្ពុជា អាចជឿ

ជាក់បាន លុះត្រាតែមានការពិនិត្យលើអង្គហេតុនិងច្បាប់ និងបរិបទជាក់ស្តែង ជាមួយនឹងប្រភពព័ត៌មានដែលបានផ្ទៀងផ្ទាត់ ព្រមទាំងប្រកាន់យកទស្សនៈទូទៅជារួម។

១៣. ការចោទប្រកាន់ថា វិធានការច្បាប់បានសំដៅលើតែសកម្មជនបក្សប្រឆាំងនិងអ្នកការពារសិទ្ធិមនុស្ស គឺជាទស្សនៈរើសអើង និងបំភាន់។ ពលរដ្ឋគ្រប់រូបមានភាពស្មើគ្នាចំពោះមុខច្បាប់ ដោយពុំប្រកាន់និន្នាការនយោបាយ មុខងារ ឬឋានៈសង្គម ដូចមានចែងក្នុងមាត្រា៣១ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។ ការចូលរួមជាមួយគណបក្សនយោបាយ ឬ អង្គការមិនមែនរដ្ឋាភិបាលណាមួយ ពុំមែនជាការផ្តល់សិទ្ធិអោយបុគ្គលណាម្នាក់បំពានច្បាប់ ដោយនិទណ្ឌភាពឡើយ។ បទល្មើសដែលមានចែងក្នុងច្បាប់ គឺជាបទល្មើស ហើយវាមិនអាចត្រូវបានប្រើវាជាទល្បីករណ៍ ក្នុងគោលបំណងផ្សេងទៀតបានឡើយ។ តុលាការនៅកម្ពុជាកាត់សេចក្តី ដោយផ្អែកលើភស្តុតាងរឹងមាំ មិនមែនផ្អែកលើដំណឹងចចាមអារ៉ាមឡើយ។

១៤. នៅចុងបញ្ចប់នេះ រាជរដ្ឋាភិបាលកម្ពុជានៅបន្តធានាអោយមានការអនុវត្តសិទ្ធិនិងសេរីភាពទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និងស្ថិតក្នុងក្របខណ្ឌនីតិរដ្ឋ ហើយនៅបន្តតាំងចិត្តឥតងាករេក្នុងដំណើរប្រជាធិបតេយ្យរបស់ខ្លួន ដែលលក្ខណៈជារបស់កម្ពុជា ដើម្បីធានាថា ការអភិវឌ្ឍប្រកបដោយចីរភាពរបស់កម្ពុជា នឹងបន្តដំណើរឆ្ពោះទៅមុខដោយមិនមានការរាំងស្ទះ ហើយសន្តិភាពដែលទទួលបានដោយលំបាក ត្រូវបានរក្សានិងការពារបានគង់វង្ស។

សូមអរគុណ!